ថ្ងៃទី២៧ ខែមេសាឆ្នាំ២០០៩

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះសាលាដំបូងសម្រេចពន្យារយៈពេលកំណត់លើសេចក្តីសម្រេចលើសំណើសុំដោះលែង កាំង ហ្គេកអ៊ាវ ហៅឌុចដោយមានលក្ខខណ្ឌ

អង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩ដើម្បីពន្យារយៈពេលកំណត់ក្នុងការសម្រេចលើសំណើសុំដោះលែងជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅឌុច ដោយបន្ថែមរយៈពេលកំណត់ចំនួន៤៥ ថ្ងៃ គឺរហូតដល់ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៩។

កាំង ហ្គេកអ៊ាវ ត្រូវបានដាក់ឲ្យស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នដោយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ចាប់តាំងពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧។ សវនាការលើអង្គសេចក្តីរបស់ជនជាប់ចោទបានចាប់ផ្តើមកាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ហើយនាថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ សហមេធាវីការពារក្តីបានដាក់សំណើ ដោយផ្ទាល់មាត់ស្នើសុំឲ្យមានការដោះលែងជនជាប់ចោទដោយមានលក្ខខណ្ឌក្នុងកំឡុងពេលសវនាការជំនុំជម្រះ។

យោងតាមវិធាន ៨២ (៣) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចឲ្យបានឆាប់តាមតែអាចធ្វើទៅបាន និងនៅក្នុងគ្រប់ករណីទាំងអស់ត្រូវសម្រេចក្នុងរយៈពេលមិនឲ្យលើសពី៣០ (សាមសិប)ថ្ងៃ បន្ទាប់ពីទទួលបានពាក្យសុំដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ លើកលែងតែមានកាលៈទេសៈពិសេស ដែលតម្រូវឲ្យមានរយៈពេលយូរជាងនេះ។

អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា សំណើសុំឲ្យដោះលែងធ្វើឡើងដោយផ្អែកលើការចោទប្រកាន់ជាច្រើន ដែលក្នុងនោះ មានការចោទប្រកាន់ដែលថាការឃុំខ្លួនជនជាប់ចោទត្រូវបានពន្យាពេលដោយមិនត្រឹមត្រូវ និងថាការឃុំខ្លួននៅអ.វ.ត.ក គឺជាការបន្តការឃុំខ្លួនរបស់តុលាការយោធាដែលបានធ្វើឡើងកាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩។

ក្នុងគោលបំណងដើម្បីវាយតម្លៃលើការអះអាងទាំងនេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាគឺជាការចាំបាច់ត្រូវពិនិត្យមើលសំណុំរឿងរបស់តុលាការយោធា។

សំណុំរឿងទាំងមូលមកពីតុលាការយោធាដែលអ.វ.ត.កទទួលបាននាថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩

គឺជាភាសាខ្មែរ ហើយចាំបាច់ត្រូវមានការបកប្រែទៅជាភាសាអង់គ្លេស និងបារាំង។ ដោយពិនិត្យទៅលើរយៈពេលក្នុងការបកប្រែភាសានិងដើម្បីទុកពេលវេលាគ្រប់គ្រាន់ដល់ភាគីទាំងអស់សម្រាប់ឆ្លើយតប និងដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចមួយដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់និងមានសំអាងហេតុផលច្បាស់លាស់ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មានកាលៈទេសៈពិសេសដែលតម្រូវឲ្យមានការពន្យារយៈពេលកំណត់ដើម្បីចេញសេចក្តីសម្រេចលើសំណើសុំឲ្យដោះលែងជនជាប់ចោទនៅក្រៅឃុំបាន។

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអាចស្វែងរកបាននៅក្នុងគេហទំព័រ
http://www.eccc.gov.kh/khmer/cabinet/courtDoc/270/E39_4_KH.pdf

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង**

លោកឡាស អូលសិន
មន្ត្រីទទួលផ្នែកទំនាក់ទំនងផ្លូវច្បាប់
ទូរស័ព្ទចល័តលេខ +855 (0) 12 488 023
ទូរស័ព្ទលេខ +855 (0) 23 219 814 លេខបន្ត 6169
សារអេឡិចត្រូនិច olsen@un.org

បណ្ឌិត ហេឡិន ចារវីស
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855 (0) 12 488 134
សារអេឡិចត្រូនិច helen.jarvis@eccc.gov.kh

លោករាជ សម្បត្តិ
មន្ត្រីទទួលបន្ទុកផ្នែកព័ត៌មាន
ទូរស័ព្ទចល័តលេខ +855 (0) 12 488 156
សារអេឡិចត្រូនិច reach.sambath@eccc.gov.kh